Washington State Department of Social & Health Services
Transforming lives

# ផ្នែករដ្ឋបាលរបស់កុមារ
# ព័ត៌មានផ្ទាល់ខ្លួន

CHILDREN'S ADMINISTRATION

# Personal Information

| ឈ្មោះ |
| --- |
| |

វាមានសារសំខាន់ដែលបុគ្គលិកផ្នែកធនធានទទួលអាជ្ញាប័ណ្ណ (DLR) បំពេញការសិក្សាអំពីស្ថានភាពគ្រួសាររបស់អ្នកដើម្បីស្គាល់អ្នក។ សំណួរទាំងនេះអំពី សាវតារគ្រួសាររបស់អ្នក ការអប់រំ ការងារ ចំណាប់អារម្មណ៍ គុណតម្លៃ រចនាបថក្នុងការរស់នៅ ទំនាក់ទំនង គំនិតអំពីការចិញ្ចឹមកូន និងការចូលរួមក្នុង សាសនា គឺជាជំហានដំបូងនៅក្នុងដំណើរការនោះ។ ពុំមានចម្លើយដែលត្រឹមត្រូវ ឬខុសឆ្គងនោះទេ។ ប្រសិនបើមានសំណួរដែលអ្នកមានបំណងធ្វើការ ពិភាក្សាដោយផ្ទាល់ សូមបញ្ជាក់អំពីបំណងនេះនៅក្នុងចន្លោះទំនេរដែលបានផ្តល់ជូន។

អ្នកផ្តល់អាជ្ញាប័ណ្ណ DLR/បុគ្គលិកធ្វើការសិក្សាអំពីស្ថានភាពគ្រួសាររបស់អ្នកនឹងត្រួតពិនិត្យព័ត៌មានឡើងវិញមុនពេលចាប់ផ្តើមធ្វើការសិក្សាអំពីស្ថានភាព គ្រួសាររបស់អ្នក ហើយនឹងប្រើប្រាស់វាជាមូលដ្ឋានសម្រាប់ការពិភាក្សាក្នុងអំឡុងពេលដំណើរការធ្វើបទសម្ភាសន៍។ សូមធ្វើការរៀបរាប់នៅក្នុងចម្លើយ នានារបស់អ្នក។

ប្រសិនបើអ្នកមានបំណងបំពេញទម្រង់បែបបទនេះតាមប្រព័ន្ធអេឡិចត្រូនិច អ្នកអាចដោនឡូតទម្រង់បែបបទនេះពី ៖

[https://www.dshs.wa.gov/fsa/forms?field_number_value=&title=&=Apply](https://www.dshs.wa.gov/fsa/forms?field_number_value=&title=&=Apply) បញ្ចូលលេខទម្រង់បែបបទ **15-276** ដើម្បីដោនឡូតទម្រង់បែបបទនេះ។ អ្នកអាចផ្ញើសំណៅដែលមានចុះហត្ថលេខាមួយច្បាប់ទៅកាន់អ្នកផ្តល់អាជ្ញាប័ណ្ណ/បុគ្គលិកធ្វើការសិក្សាអំពីស្ថានភាពគ្រួសាររបស់អ្នក តាមរយៈអ៊ីមែល និង/ឬផ្តល់ជូនពួកគេនូវសំណៅជាឯកសារមួយច្បាប់។

អ្នកដាក់ពាក្យសុំ/អ្នកផ្តល់ការថែទាំម្នាក់ៗចាំបាច់ត្រូវតែបំពេញទម្រង់បែបបទនេះ។ ប្រសិនបើអ្នកមានការលំបាកក្នុងការឆ្លើយតបទៅនឹងផ្នែកណាមួយនៃ កម្រងសំណួរនេះ ឬត្រូវការជំនួយបន្ថែម សូមពិភាក្សាអំពីចំណុចនេះជាមួយអ្នកផ្តល់អាជ្ញាប័ណ្ណ/បុគ្គលិកធ្វើការសិក្សាអំពីស្ថានភាពគ្រួសាររបស់អ្នក។

## មូលហេតុសម្រាប់ការដាក់ពាក្យសុំ

1. ហេតុអ្វីបានជាអ្នកចង់ក្លាយជាឪពុក/ម្តាយដែលផ្តល់ការទំនុកបម្រុង ឬជាអ្នកមើលថែទាំដោយគ្មានអាជ្ញាប័ណ្ណរបស់កុមារដែលស្ថិតនៅក្នុងការថែទាំ ខាងក្រៅផ្ទះ?

## A. សាវតាររបស់អ្នកដាក់ពាក្យសុំ

ការពិតអំពីគ្រួសារ ៖

1. តើអ្នកបានកើត និងត្រូវបានចិញ្ចឹមនៅកន្លែងណា?
2. សូមបញ្ជាក់ឈ្មោះ និងទំនាក់ទំនងរបស់បុគ្គលដែលបានចិញ្ចឹមអ្នក ៖
3. សូមធ្វើការពណ៌នាអំពីទំនាក់ទំនងរវាងអ្នក និងឪពុកម្តាយ/អ្នកមើលថែទាំអ្នកនៅពេលដែលអ្នកកំពុងធំលូតលាស់ និងទំនាក់ទំនងនាពេលបច្ចុប្បន្ន របស់អ្នក។
4. សូមរៀបរាប់ឈ្មោះ អាយុ និងទីតាំងរបស់បងប្អូនបង្កើតរបស់អ្នកទាំងអស់។ តើអ្នកមានទំនាក់ទំនងជាមួយការធំលូតលាស់របស់បងប្អូនបង្កើតរបស់អ្នក យ៉ាងដូចម្តេចខ្លះ និងតើទំនាក់ទំនង និងការទាក់ទងរបស់អ្នកនាពេលបច្ចុប្បន្នមានលក្ខណៈយ៉ាងដូចម្តេចខ្លះ?
5. តើកុមារដែលត្រូវបានដាក់ឲ្យស្នាក់នៅក្នុងផ្ទះរបស់អ្នកនឹងទទួលបានការប្រាស្រ័យទាក់ទងអ្វីខ្លះជាមួយបងប្អូនបង្កើតរបស់អ្នក? តើមានកង្វល់ណាមួយដែរ ឬទេ?

6. សូមធ្វើការពណ៌នាអំពីកុមារភាពរបស់អ្នក ហើយតើវាមានលក្ខណៈដូចម្តេចខ្លះនៅពេលរស់នៅក្នុងផ្ទះរបស់អ្នក។

7. សូមធ្វើការពណ៌នាអំពីបុគ្គលិកលក្ខណៈរបស់អ្នក តាមដែលអ្នកមើលឃើញខ្លួនអ្នក។

8. សូមធ្វើការពណ៌នាថាតើក្រុមគ្រួសារ និងមិត្តភ័ក្តិរបស់អ្នកមើលឃើញថាអ្នកជាមនុស្សបែបណា។

ការអប់រំ ៖

1. តើអ្នកបានបញ្ចប់ការសិក្សាកម្រិតខ្ពស់បំផុតនៅកម្រិតណា?

2. សូមរៀបរាប់សញ្ញាបត្រ/វិញ្ញាបនបត្រនានា រួមជាមួយកាលបរិច្ឆេទដែលអ្នកទទួលបាន និងពីសាលារៀន/វិទ្យាស្ថានណាខ្លះ (រួមបញ្ចូលទាំង GED ឬ វិញ្ញាបនបត្រមធ្យមសិក្សាទុតិយភូមិផងដែរ)។

3. តើមានការរំពឹងទុកអ្វីខ្លះពាក់ព័ន្ធនឹងការអប់រំដែលអ្នកមានសម្រាប់កូនៗនៅក្នុងផ្ទះរបស់អ្នក?

ប្រវត្តិការងារ/សេវាយោធា ៖

1. តើអ្នកធ្លាប់បម្រើសេវាយោធាដែរឬទេ? ☐ បាទ/ចាស ធ្លាប់ ☐ ទេ មិនធ្លាប់ទេ

   ចាប់ពី ______________________ រហូតដល់ ៖ ______________

   សាខាកងកម្លាំងប្រដាប់អាវុធ ______________________________ ឋានន្តរស័ក្តិ ______________

   ប្រភេទនៃការបំពេញភារកិច្ច ______________________________

2. សូមធ្វើការពណ៌នាអំពីប្រវត្តិការងាររបស់អ្នកដោយចាប់ផ្តើមពីការងារបច្ចុប្បន្នរបស់អ្នក។

3. សូមរៀបរាប់អំពីថ្ងៃ និងម៉ោងនៃសប្ដាហ៍ធ្វើការធម្មតារបស់អ្នក។

4. សូមធ្វើការពណ៌នាអំពីរបៀបដែលការដាក់កុមារម្នាក់ឲ្យស្នាក់នៅក្នុងផ្ទះរបស់អ្នកអាចមានផលប៉ះពាល់ចំពោះកាលវិភាគធ្វើការរបស់អ្នក។

5. តើអ្នកមានផែនការអ្វីខ្លះចំពោះការមើលថែទាំកុមារ?

6. កុមារដែលស្ថិតនៅក្នុងការថែទាំខាងក្រៅផ្ទះ ទំនងជាមានការណាត់ជួបជាមួយគ្រូពេទ្យ ការចុះសួរសុខទុក្ខ និងត្រូវធ្វើការងារផ្សេងៗ។
សូមធ្វើការពណ៌នាអំពីរបៀបដែលអ្នកនឹងដោះស្រាយជាមួយបញ្ហាទាំងនេះស្របតាមពេលវេលារបស់អ្នក។

គុណតម្លៃ គោលដៅ ចំណាប់អារម្មណ៍ និងសកម្មភាពទាំងនោះ ៖

1. សូមធ្វើការពណ៌នាអំពីគុណតម្លៃរបស់អ្នក។

2. សូមធ្វើការពណ៌នាអំពីគោលដៅផ្ទាល់ខ្លួន និងគោលដៅចំពោះគ្រួសាររបស់អ្នក។

3. តើអ្នកមានចំណាប់អារម្មណ៍ និងមានសកម្មភាពកំសាន្តអ្វីខ្លះ?

កេរ្តិ៍តំណែលវប្បធម៌

1. តើអ្នកផ្ដល់តម្លៃយ៉ាងដូចម្ដេចខ្លះចំពោះវប្បធម៌នៅក្នុងគ្រួសាររបស់អ្នកផ្ទាល់? សារៈតារផ្នែកវប្បធម៌របស់មនុស្សម្នាក់រួមបញ្ចូលវត្ថុនានា ដូចជា ប្រពៃណី គ្រួសារ ទំនៀមទម្លាប់ សាសនា ជាតិពន្ធុ និងរចនាបថក្នុងការរស់នៅ។

2. សូមធ្វើការពណ៌នាអំពីរបៀបដែលអ្នកនឹងជួយថែទាំកុមារ និងធ្វើការកោតសរសើរចំពោះកេរ្តិ៍តំណែលរបស់គាត់/នាង។

3. តើភាសាចម្បងរបស់អ្នកជាភាសាអ្វី?

តើអ្នកអាចនិយាយភាសាផ្សេងទៀតបានយ៉ាងស្ទាត់ជំនាញដែរឬទេ? ☐ បាទ/ចាស អាច ☐ ទេ មិនអាចទេ

ប្រសិនបើអាច តើជាភាសាអ្វី?

## B. ទំនាក់ទំនង

ស្វាមី/ភរិយា/ដៃគូ ៖

1. សូមធ្វើការពណ៌នាអំពីប្រវត្តិទំនាក់ទំនងសំខាន់ៗរវាងអ្នក និងដៃគូរៀបអាពាហ៍ពិពាហ៍របស់អ្នក/ដៃគូភេទដូចគ្នា/ដៃគូរស់នៅបែបអនីតិសង្វាសរបស់ អ្នក។ រួមបញ្ចូលទាំងកាលបរិច្ឆេទរៀបអាពាហ៍ពិពាហ៍ លែងលះ/ការទុកជាមោឃៈ/ការរំលាយអាពាហ៍ពិពាហ៍ និងមូលហេតុដែលធ្វើឲ្យទំនាក់ទំនង នោះត្រូវបញ្ចប់ផងដែរ ប្រសិនបើមាន។

2. ប្រសិនបើមិនបានរៀបអាពាហ៍ពិពាហ៍ សូមធ្វើការពណ៌នាអំពីទំនាក់ទំនងណាមួយដែលអាចមានផលប៉ះពាល់ដល់ការថែទាំកុមាររបស់អ្នក។

3. សូមធ្វើការពណ៌នាអំពីដៃគូរបស់អ្នក។

4. តើការសម្រេចចិត្តត្រូវបានធ្វើឡើងយ៉ាងដូចម្តេច ហើយអ្នកដោះស្រាយភាពខុសគ្នារវាងអ្នក និងដៃគូរបស់អ្នកយ៉ាងដូចម្តេច?

5. តើអ្នកនឹងមានអារម្មណ៍យ៉ាងណា ហើយអ្នកនឹងធ្វើអ្វីខ្លះ ប្រសិនបើកុមារដែលត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការថែទាំរបស់អ្នកក្លាយជាមានឥទ្ធិពលក្នុង ការបង្កការរំខានចំពោះទំនាក់ទំនងរបស់អ្នក?

កូន ៖ (ប្រសិនបើអ្នកគ្មានកូន សូមរំលងទៅកាន់ផ្នែកបន្ទាប់)

1. សូមធ្វើការពណ៌នាអំពីកូនៗរបស់អ្នកទាំងអស់ (អនីតិជន និងមនុស្សពេញវ័យ) ដែលរួមបញ្ចូលទាំងអាយុ និងទីតាំងភូមិសាស្ត្ររបស់ពួកគេផងដែរ។

2. ប្រសិនបើកូនរបស់អ្នកមានតម្រូវការពិសេស ឬការធ្វើរោគវិនិច្ឆ័យ តើតម្រូវការរបស់ពួកគេត្រូវបានបំពេញតាមដោយរបៀបណា?

3. តើការដាក់កុមារថ្មីម្នាក់ (ច្រើននាក់) នៅក្នុងផ្ទះរបស់អ្នកអាចប៉ះពាល់យ៉ាងដូចម្តេចខ្លះចំពោះដល់កូន(ៗ)របស់អ្នកផ្ទាល់?

4. ប្រសិនបើអ្នកមានកូនដែលមានអាយុក្រោម 18 ឆ្នាំដែលមិនរស់នៅជាមួយអ្នក សូមធ្វើការពណ៌នាអំពីកាលៈទេសៈនានា តើអ្នកជួបពួកគេញឹកញាប់ ប៉ុណ្ណា និងទំនួលខុសត្រូវផ្នែកហិរញ្ញវត្ថុរបស់អ្នកចំពោះកូនៗទាំងនោះ។

5. តើអ្នកមានកូនណាម្នាក់ដែលធ្លាប់មានការពាក់ព័ន្ធនឹងប្រព័ន្ធតុលាការដែរឬទេ? ប្រសិនបើមានសូមធ្វើការពណ៌នាត្រួសៗ។

ចំណុចផ្សេងៗទៀតនៅក្នុងផ្ទះរបស់អ្នក ឬចំពោះទ្រព្យសម្បត្តិរបស់អ្នក ៖

1. ផ្តល់អត្តសញ្ញាណ និងផ្តល់ការពណ៌នាត្រួសៗអំពីអ្នកណាម្នាក់ដែលរស់នៅក្នុងផ្ទះរបស់អ្នក ឬនៅលើទ្រព្យសម្បត្តិរបស់អ្នក។ សូមធ្វើការពណ៌នាអំពីរបៀបដែលពួកគេអាចមានអន្តរកម្មជាមួយកុមារណាម្នាក់ដែលត្រូវបានដាក់ឲ្យស្នាក់នៅជាមួយអ្នក។

តើពួកគេនឹង ៖ ផ្តល់ការថែទាំណាមួយដល់កុមារនោះដែរឬទេ? ☐ បាទ/ចាស ☐ ទេ

ដឹកជញ្ជូនកុមារដែរឬទេ? ☐ បាទ/ចាស ☐ ទេ

ផ្តល់ការត្រួតពិនិត្យណាមួយដល់កុមារដែរឬទេ? ☐ បាទ/ចាស ☐ ទេ

មានការប្រាស្រ័យទាក់ទងដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងជាមួយកុមារដែរឬទេ? ☐ បាទ/ចាស ☐ ទេ

## C. ការចិញ្ចឹមបីបាច់កូន និងបទពិសោធន៍ជាមួយកូន

វិន័យ ៖

1. តើអ្នកទទួលបានការដាក់វិន័យយ៉ាងដូចម្តេចខ្លះក្នុងនាមជាកូនម្នាក់?

2. សូមធ្វើការពណ៌នាអំពីការអនុវត្តការដាក់វិន័យនាពេលបច្ចុប្បន្ន និងជំនឿនានារបស់អ្នក (កុមារដែលស្ថិតនៅក្នុងការថែទាំខាងក្រៅផ្ទះប្រហែលជាមិន អាចទទួលការដាក់វិន័យផ្នែករាងកាយបាននោះទេ)។

បទពិសោធន៍ និងការបណ្តុះបណ្តាល ៖

1. សូមធ្វើការពណ៌នាអំពីបទពិសោធន៍របស់អ្នកជាមួយកុមារផ្សេងទៀតក្រៅពីកូនរបស់អ្នកផ្ទាល់។ តើអ្នកមានបទពិសោធន៍ធ្វើការជាមួយកុមារដែលមាន តម្រូវការពិសេសដែរឬទេ?

2. តើអ្នកមានបំណងចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលដែរឬទេ? ☐ បាទ/ចាស ☐ ទេ។ ប្រសិនបើមាន តើអ្នកមានបំណងទទួលបានការ បណ្តុះបណ្តាលផ្នែកណាខ្លះ?

ឥរិយាបថចំពោះការចិញ្ចឹមបីបាច់កូន ៖

1. តើអាកប្បកិរិយា និងគុណភាពអ្វីខ្លះដែលអ្នកចូលចិត្តខ្លាំងបំផុតនៅក្នុងខ្លួនកុមារ?

2. តើអាកប្បកិរិយា ឬគុណភាពអ្វីខ្លះដែលអ្នករកឃើញថាមានបញ្ហាប្រឈមខ្លាំងបំផុតនៅក្នុងខ្លួនកុមារ? សូមធ្វើការពណ៌នាអំពីស្ថានភាពដែលអ្នក រកឃើញថាមានបញ្ហាប្រឈមខ្លាំងបំផុតក្នុងភាពជាឪពុក/ម្តាយម្នាក់។ សូមធ្វើការពណ៌នាអំពីរបៀបដែលអ្នកបានដោះស្រាយបញ្ហាទាំងនេះ។

3. តើបញ្ហាប្រឈមអ្វីខ្លះដែលអ្នករំពឹងទុកថានឹងកើតមានឡើងក្នុងការចិញ្ចឹមបីបាច់កុមារដែលត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការថែទាំរបស់អ្នក?

4. សូមធ្វើការពណ៌នាអំពីកូនដែលអ្នកមើលឃើញតាមរយៈការចិញ្ចឹមបីបាច់ដោយខ្លួនអ្នកផ្ទាល់ ដែលរួមបញ្ចូលទាំងអាយុ ភេទ/យេនឌ័រ ភាសា សុខភាព ការអភិវឌ្ឍ។ល។

5. សូមធ្វើការពណ៌នាអំពីរបៀបដែលអ្នកនឹងចិញ្ចឹមបីបាច់ និងផ្តល់ការថែទាំដល់កុមារណាម្នាក់ដែលមានជាតិសាសន៍ វប្បធម៌ ឬទំនោរផ្លូវភេទខុសគ្នាពី ខ្លួនអ្នក?

6. សូមធ្វើការពណ៌នាអំពីរបៀបដែលអ្នកនឹងចែករំលែកទំនួលខុសត្រូវក្នុងការចិញ្ចឹមបីបាច់ជាមួយគ្រួសាររបស់អ្នក។

7. សូមធ្វើការពណ៌នាអំពីពេលវេលាណាមួយនៅក្នុងជីវិតរបស់អ្នកដែលអ្នកបានបាត់បង់មនុស្សសំខាន់ម្នាក់ និងរបៀបដែលអ្នកដោះស្រាយជាមួយការ បាត់បង់នេះ។ តើការបាត់បង់នេះមានទំនាក់ទំនងយ៉ាងដូចម្តេចខ្លះទៅនឹងជាមួយរបៀបដែលកុមារដែលត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការថែទាំរបស់អ្នក អាចមានអារម្មណ៍?

8. តើអ្នកមានការយល់ដឹងយ៉ាងដូចម្តេចខ្លះចំពោះរបួស ឬការបាត់បង់ដែលកុមារម្នាក់អាចឆ្លងកាត់នៅពេលត្រូវបានដាក់ឲ្យស្ថិតនៅក្នុងការថែទាំ ខាងក្រៅផ្ទះ។

9. តើអ្នកនឹងមានបំណងចូលរួមនៅក្នុងការប្រឹក្សាយោបល់ជាមួយកុមារដែលត្រូវបានដាក់ឲ្យស្នាក់នៅក្នុងផ្ទះរបស់អ្នកដែរឬទេ? ☐ បាទ/ចាស ☐ ទេ

សកម្មភាព/វិធានគ្រួសារ ៖

1. តើគ្រួសាររបស់អ្នកធ្វើអ្វីខ្លះដើម្បីជាការកំសាន្ត? តើអ្នកនឹងរួមបញ្ចូលកុមារដែលស្ថិតនៅក្នុងការថែទាំខាងក្រៅផ្ទះចូលទៅក្នុងសកម្មភាពគ្រួសារធម្មតា បានដោយរបៀបណា?

2. តើវិធានគ្រួសាររបស់អ្នកមានអ្វីខ្លះ (ការអនុញ្ញាត ឯកជនភាព ពេលវេលាចូលគេង បម្រាមគោចរ។ល។)?

## D. ការចូលរួម និងការអនុវត្តផ្នែកសាសនា/វិញ្ញាណ

1. សូមធ្វើការពណ៌នាអំពីការចូលរួម និងការអនុវត្តផ្នែកសាសនា/វិញ្ញាណរបស់អ្នក ប្រសិនបើមាន។

2. តើអ្នកមានការរំពឹងទុកយ៉ាងដូចម្តេចខ្លះអំពីការអនុវត្តផ្នែកសាសនា/វិញ្ញាណសម្រាប់កុមារដែលត្រូវបានដាក់ឲ្យស្នាក់នៅក្នុងផ្ទះរបស់អ្នក?

## E. ផ្នែកវេជ្ជសាស្ត្រ/ផ្នែកផ្លូវចិត្ត និងសង្គម

1. តើអ្នក ឬសមាជិកគ្រួសារណាម្នាក់ធ្លាប់ប្រើប្រាស់ថ្នាំខុសច្បាប់ ឬធ្លាប់បំពានលើការប្រើប្រាស់ថ្នាំស្របច្បាប់ដែរឬទេ? ☐ បាទ/ចាស ☐ ទេ
   ប្រសិនបើធ្លាប់ សូមគូសថាតើជាសមាជិកណាម្នាក់ ៖

| | | | |
|---|---|---|---|
| ☐ ខ្លួនអ្នក | ☐ ឪពុក | ☐ ជីដូន | ☐ ក្មួយប្រុស |
| ☐ ស្វាមី/ភរិយា ឬដៃគូ | ☐ ម្តាយចុង | ☐ ជីតា | ☐ បងប្អូនជីដូនមួយ |
| ☐ កូនប្រុស | ☐ ឪពុកចុង | ☐ មីង | ☐ សាច់ថ្លៃ |
| ☐ កូនស្រី | ☐ បង/ប្អូនប្រុស | ☐ ពូ | ☐ ផ្សេងៗ ៖ |
| ☐ ម្តាយ | ☐ បង/ប្អូនស្រី | ☐ ក្មួយស្រី | |

2. ដោយមិនគិតថាតើវាកន្លងមកយូរប៉ុណ្ណាហើយក៏ដោយ តើអ្នក ឬអ្នកណាម្នាក់នៅក្នុងគ្រួសាររបស់អ្នកធ្លាប់ឆ្លងកាត់បញ្ហាណាមួយដូចខាងក្រោមដែរឬទេ ៖

☐ បាទ/ចាស ☐ ទេ បញ្ហាសុខភាពផ្លូវកាយ
☐ បាទ/ចាស ☐ ទេ បញ្ហាសុខភាពខួរក្បាល និង/ឬការព្យាបាល
☐ បាទ/ចាស ☐ ទេ ការសេពគ្រឿងញៀន ឬគ្រឿងស្រវឹង និង/ឬការព្យាបាល
☐ បាទ/ចាស ☐ ទេ អំពើហិង្សាក្នុងគ្រួសារ
☐ បាទ/ចាស ☐ ទេ ការផ្តល់ការប្រឹក្សាយោបល់ បុគ្គល និង/ឬអ្នកដទៃទៀត (គ្រួសារ ក្រុម។ល។)
☐ បាទ/ចាស ☐ ទេ ការប្រយុទ្ធផ្នែកយោធា
☐ បាទ/ចាស ☐ ទេ ការរលូតកូន ឬអសមត្ថភាពក្នុងការបង្កកំណើត

☐ បាទ/ចាស ផ្សេងៗ សូមរៀបរាប់ ៖

ពន្យល់អំពីចម្លើយ “បាទ/ចាស” ណាមួយដែលរួមបញ្ចូលទាំងរោគវិនិច្ឆ័យ កាលបរិច្ឆេទ លទ្ធផលនៃការព្យាបាល និង/ឬការពាក់ព័ន្ធនឹងការអនុវត្តច្បាប់។

3. តើអ្នក ឬសមាជិកណាម្នាក់នៃគ្រួសាររបស់អ្នកធ្លាប់បានចូលរួមនៅក្នុងសេវាការពារកុមារ (CPS) ដែរឬទេ? ☐ បាទ/ចាស ☐ ទេ

ប្រសិនបើមាន សូមពន្យល់ ៖

4. តើនៅក្នុងផ្ទះ ឬនៅក្នុងរថយន្តរបស់អ្នក អនុញ្ញាតឲ្យមានការជក់បារីដែរឬទេ? ☐ បាទ/ចាស ☐ ទេ

## F. ផ្ទះ និងសង្កាត់

1. តើអ្នកបានរស់នៅក្នុងផ្ទះ/សង្កាត់បច្ចុប្បន្នរបស់អ្នកយូរប៉ុណ្ណាហើយ?
2. តើអ្នកប្រើប្រាស់ប្រព័ន្ធទឹកសាធារណៈ ឬឯកជន?
3. តើមានសេចក្ដីអន្តរាយជាសក្ដានុពលណាមួយនៅក្នុងផ្ទះ ឬនៅលើទ្រព្យសម្បត្តិរបស់អ្នកដែរឬទេ?
4. សូមរៀបរាប់សត្វចិញ្ចឹមនៅក្នុងគ្រួសារទាំងអស់ ឬសត្វដទៃដែលស្ថិតនៅលើទ្រព្យសម្បត្តិរបស់អ្នក។
5. តើសត្វចិញ្ចឹម ឬសត្វទាំងនេះមានសុវត្ថិភាពក្នុងការនៅក្បែរកុមារដែរឬទេ? ☐ បាទ/ចាស ☐ ទេ។ ប្រសិនបើទេ តើមានផែនការអ្វីខ្លះក្នុងការធ្វើឲ្យ កុមារមានសុវត្ថិភាពក្នុងការនៅក្បែរសត្វចិញ្ចឹម ឬសត្វទាំងនេះ?

## G. ប្រព័ន្ធទ្រទ្រង់

1. តើអ្នកប្រើប្រាស់អ្នកណាសម្រាប់ការទ្រទ្រង់? សូមធ្វើការពណ៌នាអំពីពេលវេលាណាមួយដែលប្រព័ន្ធទ្រទ្រង់របស់អ្នកនៅទីនោះដើម្បីជួយអ្នក។

2. តើសមាជិកណាម្នាក់នៃប្រព័ន្ធទ្រទ្រង់របស់អ្នកនឹងមានទំនាក់ទំនងជាមួយកុមារដែលត្រូវបានដាក់ឲ្យស្នាក់នៅក្នុងផ្ទះរបស់អ្នកដែរឬទេ? ប្រសិនបើមាន សូមធ្វើការពណ៌នា។

## H. ហិរញ្ញវត្ថុគ្រួសារ

1. តើអ្នកយល់ថាអ្នកអាចថែទាំកូនម្នាក់ទៀតដោយគ្មានការទ្រទ្រង់ផ្នែកហិរញ្ញវត្ថុបន្ថែមបានដែរឬទេ? ប្រសិនបើមិនបានទេ តើអ្នកត្រូវការការទ្រទ្រង់ផ្នែក ហិរញ្ញវត្ថុអ្វីខ្លះ?

2. តើអ្នកកំពុងទទួលបានជំនួយផ្នែកហិរញ្ញវត្ថុនៅក្នុងទម្រង់ណាមួយផ្សេងទៀតដែរឬទេ? ☐ បាទ/ចាស ☐ ទេ

ប្រសិនបើ បាទ/ចាស សូមពន្យល់ ៖

## I. សក្តានុពលសម្រាប់ភាពអចិន្ត្រៃយ៍

សម្គាល់ ៖ **DLR** បំពេញការសិក្សាអំពីស្ថានភាពគ្រួសារដូចគ្នាសម្រាប់អ្នកដាក់ពាក្យសុំគ្រប់រូប។ ការសិក្សាអំពីស្ថានភាពគ្រួសារទាំងនេះឯកភាពឲ្យគ្រួសារ ដាក់កុមារឲ្យស្នាក់នៅជាមួយ និងទទួលចិញ្ចឹម។

1. សូមធ្វើការពណ៌នាអំពីរបៀបដែលអ្នកនឹងគាំទ្រ និងចូលរួមនៅក្នុងការជួបជុំគ្រួសារឡើងវិញដោយសុវត្ថិភាពរវាងកុមារ និងឪពុកម្តាយ ឬអាណាព្យាបាលរបស់គាត់/នាង។

2. សូមធ្វើការពណ៌នាអំពីការយល់ដឹងរបស់អ្នកអំពីភាពអចិន្ត្រៃយ៍សម្រាប់កុមារដែលស្ថិតនៅក្នុងការថែទាំខាងក្រៅផ្ទះ (ការត្រឡប់ទៅផ្ទះវិញ ការទទួល ចិញ្ចឹម ការទំនុកបម្រុងថែទាំរយៈពេលវែង)។

3. តើអ្នកនឹងគាំទ្រចំពោះផែនការជាអចិន្ត្រៃយ៍របស់កុមារដោយរបៀបណា នៅពេលដែលអ្នកមិនយល់ស្របចំពោះចំពោះផែនការនោះ?

4. សូមធ្វើការពណ៌នាថាតើគំនិតនៃការទទួលចិញ្ចឹម/អាណាព្យាបាលភាព/ការទំនុកបម្រុងថែទាំរយៈពេលវែង ជា “ដំណើរការ និងការប្តេជ្ញាចិត្តចំពោះ ការអភិវឌ្ឍពេញមួយជីវិត” មានអត្ថន័យដូចម្តេចចំពោះអ្នក។

5. សូមធ្វើការពណ៌នាថាតើអ្នកមានគំនិតយ៉ាងដូចម្តេចខ្លះដែលថាកុមារអាចមានអារម្មណ៍ភ័ន្តច្រឡំ និងបាត់បង់អត្តសញ្ញាណ ពាក់ព័ន្ធនឹងការបែកចេញពី ឪពុកម្តាយបង្កើត ហើយតើកុមារអាចបញ្ចេញអារម្មណ៍ ឬអាកប្បកិរិយានេះដោយរបៀបណា។ សូមធ្វើការពណ៌នាអំពីរបៀបដែលអ្នកនឹងជួយដល់ កុមារម្នាក់នៅក្នុងការដោះស្រាយជាមួយការភ័ន្តច្រឡំ និងការបាត់បង់អត្តសញ្ញាណ។

6. សូមធ្វើការពណ៌នាអំពីសារសំខាន់នៃទំនាក់ទំនងរវាងបងប្អូនបង្កើតចំពោះកុមារម្នាក់ដែលស្ថិតនៅក្នុងការថែទាំខាងក្រៅផ្ទះ។

7. ប្រសិនបើកុមារត្រូវបានដាក់ឲ្យស្នាក់នៅក្នុងផ្ទះរបស់អ្នក មិនអាចត្រឡប់ទៅផ្ទះវិញបាន តើអ្នកចាត់ទុកវាថាជាធនធាននៃការដាក់ឲ្យស្នាក់នៅជាមួយជា អចិន្ត្រៃយ៍ដែរឬទេ? សូមពន្យល់ថាហេតុអ្វីជា ឬហេតុអ្វីមិនមែនជាធនធាននៃការដាក់ឲ្យស្នាក់នៅជាមួយជាអចិន្ត្រៃយ៍។

8. តើអ្នកនឹងពិចារណាធ្វើជាធនធាននៃការដាក់ឲ្យស្នាក់នៅជាមួយសម្រាប់បងប្អូនបង្កើតរបស់កុមារម្នាក់នោះ ដែលមិនត្រូវបានដាក់ឲ្យស្នាក់នៅក្នុងផ្ទះរបស់អ្នកដែរឬទេ?

9. តើអ្នកនឹងពិចារណាអំពីការធ្វើកិច្ចព្រមព្រៀងស្តីពីការប្រាស្រ័យទាក់ទងដោយបើកចំហរមួយសម្រាប់កុមារណាម្នាក់ដែលអ្នកអាចទទួលចិញ្ចឹម មានភាព អាណាព្យាបាលលើកុមារនោះ ឬបំពេញកិច្ចព្រមព្រៀងទំនុកបម្រុងថែទាំរយៈពេលវែងជាមួយឪពុកម្តាយបង្កើត និង/ឬបងប្អូនបង្កើតដែលបានស្គាល់របស់ ពួកគេដែរឬទេ? ☐ បាទ/ចាស ☐ ទេ

សូមពន្យល់ថាហេតុអ្វីធ្វើ ឬហេតុអ្វីមិនធ្វើ។

10. សូមធ្វើការពណ៌នាអំពីផែនការដែលអ្នកនឹងធ្វើការលាតត្រដាងអំពីការទទួលចិញ្ចឹម/អាណាព្យាបាលភាព/ការទំនុកបម្រុងថែទាំទៅកាន់កុមារណា ម្នាក់។

11. សូមធ្វើការពណ៌នាអំពីវិធីដែលអ្នកនឹងដោះស្រាយជាមួយសំណួររបស់កុមារម្នាក់អំពីឪពុកម្តាយបង្កើត និងសាច់ញាតិ។

12. សូមធ្វើការពណ៌នាអំពីរបៀបដែលកេរ្តិ៍តំណែលផ្នែកជាតិសាសន៍ ជាតិពន្ធុ និងវប្បធម៌របស់កុមារម្នាក់អាចប៉ះពាល់ដល់គ្រួសារ និងកូនរបស់អ្នក។

13. សូមធ្វើការពណ៌នាអំពីផែនការរបស់អ្នក ក្នុងករណីដែលអ្នកមិនអាចផ្តល់ការថែទាំដល់កុមារដែលបានដាក់ឲ្យស្នាក់នៅក្នុងផ្ទះរបស់អ្នកបន្តទៀតបាន។

## J. កុមារដាក់លាក់

សូមបំពេញផ្នែកនេះនៅពេលដែលកុមារដែលត្រូវបានចង្អុលបង្ហាញអំពីអត្តសញ្ញាណណាម្នាក់ត្រូវបានដាក់ឲ្យស្នាក់នៅ ឬមានចេតនា ត្រូវបានដាក់ឲ្យស្នាក់នៅក្នុងផ្ទះរបស់អ្នក។

1. សូមធ្វើការពណ៌នាអំពីកុមារដាក់លាក់ដែលអ្នកអាចកំពុងដាក់ពាក្យស្នើសុំធ្វើជាធនធានដាក់ឲ្យស្នាក់នៅជាមួយ។

2. សូមធ្វើការពណ៌នាអំពីការយល់ដឹងរបស់អ្នកអំពីប្រវត្តិផាក់លាក់ និងតម្រូវការនាពេលបច្ចុប្បន្នរបស់កុមាររូបនោះ។

3. សូមធ្វើការពណ៌នាអំពីការគាំទ្រដែលអ្នកអាចត្រូវការប្រសិនបើកុមារនោះត្រូវបានដាក់ឲ្យស្នាក់នៅក្នុងផ្ទះរបស់អ្នក។

4. សូមធ្វើការពណ៌នាអំពីការយល់ដឹងរបស់អ្នកអំពីមូលហេតុដែលកុមារនោះបានចូលរួមនៅក្នុងការដាក់ឲ្យស្នាក់នៅ នៅក្រៅផ្ទះរបស់ពួកគេ។

## K. តើព័ត៌មានផ្សេងទៀតណាខ្លះដែលអ្នកមានបំណងចែករំលែកជាមួយយើង?

| | |
|---|---|
| ហត្ថលេខា | កាលបរិច្ឆេទ |